# សេរីភាពខាងការជួបប្រជុំ-(ឆ្នាំទី៦៖ ខែមករា ដល់ខែធ្នូ ឆ្នាំ២០២១)

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន("គម្រោង") ជាគម្រោងពិនិត្យមើលជាប្រព័ន្ធនូវលទ្ធភាពរបស់ពលរដ្ឋកម្ពុជាក្នុងការអនុវត្តសិទ្ធិសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ។ ព័ត៌មាននេះបង្ហាញពីរបកគំហើញសំខាន់ទាក់ទងនឹងសេរីភាពខាងការជួបប្រជុំដែលបានមកពីរបាយការណ៍ប្រចាំឆ្នាំទី៦ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាន។ ក្នុងឆ្នាំ២០២១ គម្រោងបានកត់ត្រា ការរឹតត្បិតចំនួន**៨៧** ករណីទៅលើសេរីភាពនៃការសេរីភាពខាងការជួបប្រជុំ ដែលក្នុងចំណោមនោះមាន**៦០** ករណីជាការរំលោភបំពាន។

## ជាងពាក់កណ្ដាលនៃការជួបប្រជុំក្នុងឆ្នាំ២០២១ ត្រូវបានការពារ




*ការការពារត្រូវបានកត់ត្រានៅពេលដែលបុគ្គលម្នាក់អនុវត្តសេរីភាពខាងការជួបប្រជុំបានដោយសេរី និងគ្មានការជ្រៀតជ្រែកឬការរឹតត្បិតពីអាជ្ញាធរ ឬភាគីទីបី។*

## ៥៥% នៃសាធារណជនចូលរួមស្ទង់មតិជាសាធារណៈយល់ថាថាមានសេរីភាពក្នុងការជួបប្រជុំក្នុងឆ្នាំ២០២១




## តិចជាង ១៤% នៃថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីពយល់ថាមានសេរីភាពក្នុងជួបប្រជុំក្នុងឆ្នាំ២០២១




*របកគំហើញនេះបង្ហាញថា ទោះបីជាសេរីភាពខាងការជួបប្រជុំត្រូវបានការពារយ៉ាងទូលំទូលាយយ៉ាងណា ក៏បុគ្គលម្នាក់ៗអាចមានសេរីភាពក្នុងការចូលរួមការជួបប្រជុំសម្រាប់តែការជួបប្រជុំជាក់លាក់មួយចំនួនប៉ុណ្ណោះ។*

## មនុស្សចំនួន ៧២នាក់ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ២០២១ ដោយហេតុតែពួកគេអនុវត្តសិទ្ធិនៃការជួបប្រជុំរបស់ខ្លួន




*តួលេខខ្ពស់នៃការចាប់ខ្លួនបុគ្គលដែលអនុវត្តសេរីភាពនៃការជួបប្រជុំអាចបណ្ដាលឱ្យមានការថយចុះភាគរយនៃថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីពដែលមានអារម្មណ៍ថាមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី។*

## ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពខាងការជួបប្រជុំនៅមានកម្រិតទាប




*ការយល់ឃើញរបស់សាធារណជនអំពីសេរីភាពខាងការជួបប្រជុំអាចរារាំងដល់ការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេបានពេញលេញ។*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

សមាគមអាដហុក ADHOC

SOLIDARITY CENTER

ICNL INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

CC BY NC SA

ខែមេសា ឆ្នាំ២០២២